ព្រឹត្តិបត្រផ្សព្វផ្សាយកសិកម្ម AGRICULTURAL EXTENSION BULLETIN
ចេញផ្សាយដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
A Publication by the Department of Extension for Agriculture, Forestry and Fisheries
លេខទី ១៥ ត្រីមាសទី៤ ឆ្នាំ ២០១៩
Website : http://www.khmeragri.info



# បទពិសោធន៍ជោគជ័យលើការងារចិញ្ចឹមមាន់ របស់កសិករ វិន ប៊ុនលឿ និងកសិករ សូរិយា

រស់នៅក្នុងភូមិទំនប់ត្រកួន ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះ រៀបចំឡើងក្នុងគោលបំណងចងក្រង នូវរាល់បទពិសោធន៍ជោគជ័យលើការងារ និងមុខរបរផ្សេងៗ ដែលជាស្នាដៃអនុវត្តផ្ទាល់របស់កសិករ ក៏ដូចជាសហគមន៍ និងស្ថាប័នពាក់ព័ន្ធនានា ដែលមានស្នាដៃឆ្នើមក្នុងការអនុវត្តការងារមកចងក្រង និងធ្វើការផ្សព្វផ្សាយជូនដល់ប្រជាកសិករ សហគមន៍ និងដៃគូរពាក់ព័ន្ធផ្សេងទៀតដើម្បីជាចំណេះដឹងបន្ថែមសម្រាប់ការអនុវត្តការងារ និងប្រកបរបរពាក់ព័ន្ធនឹងវិស័យកសិកម្ម។

ព្រឹត្តិប័ត្រព័ត៌មានកសិកម្មនេះដែរ បានលើកយកបទពិសោធន៍ជោគជ័យ លើការងារចិញ្ចឹមមាន់ដើម្បីបង្កើនជីវភាពគ្រួសារឱ្យប្រសើរឡើង របស់កសិករ វិន ប៊ុនលៀ និងកសិករ សូរិយា រស់នៅភូមិបឹងសង្កែរ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង ជាកសិករមានស្នាដៃល្អ លើការងារចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារមកបង្ហាញជូនដូចខាងក្រោម៖

បវេលជាស្រុកមួយក្នុងខេត្តបាត់ដំបង ដែលបច្ចុប្បន្នកំពុងមានការរីកចម្រើនលើវិស័យកសិកម្ម និងបានកែប្រែជីវភាពប្រជាជនក្នុងស្រុកមួយនេះឱ្យកាន់តែធូរធារ ភាពរីកចម្រើនទាំងអស់នេះ គឺបានមកដោយសារការយកចិត្តទុកដាក់ខ្ពស់ពីថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ត្រីជំនាញក្រោមឱវាទ ពិសេសមន្ត្រីជំនាញមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង បានចុះធ្វើការផ្សព្វផ្សាយ និងបង្ហាត់បង្រៀនប្រជាកសិករ ឱ្យចេះពីវិធីសាស្ត្រដាំដុះ ចិញ្ចឹមសត្វតាមបច្ចេកទេសថ្មីៗទំនើប តាមការឱ្យដឹងពី





គ្រួសារកសិករ វិន ប៊ុនលឿ និងកសិករ សូរិយា ដែលបានចាប់យកមុខរបរចិញ្ចឹមមាន់

លោក គឹម សុង ប្រធានការិយាល័យស្រុកបវេល ប្រជាកសិករស្រុកបវេលជាច្រើនគ្រួសារ បានទទួលចំណេះដឹងផ្នែកកសិកម្មសម្រាប់ប្រកបរបរចិញ្ចឹមជីវិត ជាក់ស្តែងនៅក្នុងឃុំឃ្លាំងមាស ស្រុកបវេលប្រជាកសិករជាច្រើនគ្រួសារបានចងក្រងគ្នាជាក្រុមក្នុងការចិញ្ចឹមមាន់ ដែលមានសមាជិករហូតដល់២៥គ្រួសារ ពួកគាត់សុទ្ធតែបានទទួលការបណ្តុះបណ្តាល ពីវិធីសាស្ត្រ

ដែលមានប្រសិទ្ធិភាពខ្ពស់ ដែលកសិករគួរតែកិនធ្វើជាចំណីសម្រាប់មាន់ ព្រោះវាជាប្រភពផ្តល់នូវថាមពល មានប្រូតេអ៊ីនពី ៩-១០% និង ជាអ្នកផ្តល់ពណ៌ (ជួយបង្កើនពណ៌លឿងនៅស្បែក និងស៊ុត) ក្រៅពីនេះនៅមានពពូក សណ្តែកសៀង មើមដំឡូងមី ស្លឹកដំឡូងមី សុទ្ធតែជាប្រភេទដំណាំដែលអាចយកមកផ្សំសម្រាប់ជាចំណីមាន់បាន។



ស្រូវ និងអង្ករ



ពោត



ដំឡូងជ្វា



កន្ទក់

សព្វថ្ងៃកសិករ **វិន ប៊ុនលៀ** មានមាន់ទាំងតូចទាំងធំចំនួន ៥០០ មាន់ ក្រោយទទួលបានភាពជោគជ័យលើការងារចិញ្ចឹមមាន់ គាត់មានការសប្បាយរីករាយយ៉ាងខ្លាំងដោយគាត់មិនមានការលំបាកផ្នែកជីវភាពទៀតទេក្នុងពេលបច្ចុប្បន្ននេះ ព្រោះអាចលក់មាន់បានពី៣០ ទៅ ៤០ក្បាលក្នុង១ខែ ដោយមិនមានការលំបាកក្នុងការរកទីផ្សារឡើយ គឺមានអតិថិជនមកទទួលទិញដល់ផ្ទះតែម្តងកសិករ **វិន ប៊ុនលៀ** បានបន្តទៀតថា ចំពោះការលក់ យើងអាចលក់ជាស៊ុតក៏បាន ជាកូនមាន់ក៏បាន ឬក៏ជាមាន់សាច់ក៏បាន ថវិកាដែលគាត់ទទួលបានពីការចិញ្ចឹមមាន់ ធ្វើឱ្យគ្រួសារគាត់មានលទ្ធភាពបញ្ជូនកូនទៅសាលារៀន និងអាចទិញសម្ភារល្អសម្រាប់ប្រើប្រាស់ក្នុងគ្រួសារបាន ពិសេសមុខរបរនេះធ្វើឱ្យក្រុមគ្រួសារបានរស់នៅជួបជុំគ្នា មិនចាំបាច់ធ្វើចំណាកស្រុក។ ជាទិសដៅបន្ត កសិករ **វិន ប៊ុនលៀ** មានគម្រោងពង្រីករោងចិញ្ចឹមមាន់បន្ថែមទៀត។



*កសិករ វិន ប៊ុនលៀ និងគ្រួសារសប្បាយរីករាយ ក្រោយទទួលបានជោគជ័យលើរបរចិញ្ចឹមមាន់*

ចំណែកកសិករ **ស្ទើរិយា** ដែលមានទីលំនៅក្នុង ភូមិបឹងសង្កែរ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង ក៏ជាកសិករម្នាក់ស្ថិតក្នុងក្រុមទាំង២៥ គ្រួសារដែលទទួលជោគជ័យក្នុងការចិញ្ចឹមមាន់ មិនចាញ់កសិករដទៃទៀតឡើយ។ កសិករ **ស្ទើរិយា** បានប្រាប់ឱ្យដឹងថាការផ្លាស់ប្តូររបរទទួលទានពីការធ្វើស្រែ និងចិញ្ចឹមមាន់បន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ មកជាការចិញ្ចឹមមាន់តាមបច្ចេកទេសថ្មីនេះជាមុខរបរចម្បងសម្រាប់គ្រួសារវិញ បច្ចុប្បន្នកសិករ **ស្ទើរិយា** អាចទទួលបានប្រាក់ចំណូលពី១,០០០,០០០ ទៅ១,៥០០០,០០០ រៀលក្នុងមួយខែ ហើយដែលសព្វថ្ងៃនេះកសិករ **ស្ទើរិយា** បានចិញ្ចឹមមាន់រហូតដល់ទៅជាង ៥០០ ក្បាល និងបានលក់ជាកូនមាន់ផង និងមាន់សាច់ផង។



**សម្រាប់ព័ត៌មានលម្អិតសូមទំនាក់ទំនងមក៖**

- មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង
- កសិករ **វិន ប៊ុនលៀ** រស់នៅភូមិទំនប់ត្រកួន និងកសិករ **ស្ទើរិយា** រស់នៅភូមិបឹងសង្កែរ ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង

ទំនាក់ទំនងទូរស័ព្ទលេខ៖ ០១២ ៧០១ ៨៣៣

ចិញ្ចឹមមាន់ ពីមន្ត្រីជំនាញស្រុកបវេល ជាលទ្ធផលកសិករ **វិន ប៊ុនលឿ** និងកសិករ **សូរីយា** បច្ចុប្បន្នកំពុងទទួលបានភាពជោគជ័យយ៉ាងខ្លាំងលើការងារចិញ្ចឹមមាន់ តាមលក្ខណៈបច្ចេកទេស។

### ១. អំពីប្រវត្តិ

កសិករ **វិន ប៊ុនលឿ** រស់ភូមិទំនប់ត្រកួន ឃុំឃ្លាំងមាស ស្រុកបវេល ខេត្តបាត់ដំបង បានឱ្យដឹងថាកាលពីពេលមុនរូបលោកជាអ្នកប្រកបរបរជុំតញ្ចុងលក់ និងធ្វើស្រែតែដោយសារមុខរបរនេះមានការលំបាក និងនឿយហត់ពេក លោកក៏មានបំណងធ្វើការផ្លាស់ប្តូរមុខរបរ គាប់ជួនមានការចុះមកបើកវគ្គបណ្តុះបណ្តាលអំពីបច្ចេកទេសចិញ្ចឹមមាន់ របស់មន្ត្រីជំនាញមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខេត្តបាត់ដំបង កសិករ **វិន ប៊ុនលឿ** ក៏សម្រេចចិត្តចុះឈ្មោះចូលរៀន ក្នុងវគ្គបណ្តុះបណ្តាលនោះតែម្តង ចាប់តាំងពីពេលនោះមកលោកបានចាប់ផ្តើមចិញ្ចឹមមាន់ រហូតទទួលបានជោគជ័យ ដូចសព្វថ្ងៃនេះ ដោយបច្ចុប្បន្នការចិញ្ចឹមមាន់របស់លោក បានកើនឡើងរហូតដល់៥០០ក្បាល។ កសិករ **វិន ប៊ុនលឿ** បានរំលឹកឡើងវិញថា សព្វថ្ងៃគាត់មានមុខរបរធ្វើស្រែ និងចិញ្ចឹមមាន់ ដោយសារមុខរបរនេះមានភាពងាយស្រួលជាង លោកបានឱ្យដឹងបន្ថែមទៀតថា ការចេះពីបច្ចេកទេសចិញ្ចឹមមាន់នេះ ក៏ដោយសារបានទទួលការបណ្តុះបណ្តាល ពីមន្ត្រីជំនាញកសិកម្មស្រុក ចុះមកបង្ហាត់បង្ហាញដែលបច្ចេកទេសទាំងនោះមានដូចជា៖ បច្ចេកទេសជ្រើសរើសពូជ ការសាងសង់ទ្រុង ការធ្វើអនាម័យ ការធ្វើវ៉ាក់សាំង ការភ្ញាស់ និងវិធីផ្សំចំណីជាដើម ។ កសិករ **វិន ប៊ុនលឿ** បានប្រាប់ពីវិធីសាស្ត្រនៃការចិញ្ចឹមតាមដំណាក់កាលនីមួយៗថា ចំពោះការជ្រើសរើសកូនមាន់យកមកចិញ្ចឹមត្រូវមានរាងល្អ ត្លៀវក្លា ជើងលឿង ចំពោះកូនមាន់ដែលមានរោមស្អិតជាប់គ្នា ហើយពោះធ្លាក់ប្រឹង និងមានព័ណខៀវ មិនគួរយកមកចិញ្ចឹមទេ។ ការជ្រើសរើសបាមាន់ត្រូវមានរាងល្អ ត្លៀវក្លា ជើងលឿង មាឌធំ ទម្ងន់ ២,៥ គីឡូក្រាម ពូកែជាន់មេ (បង្កាត់ពូជ)មានអាយុចាប់ពី ៩ ខែ ឡើង តែមិនត្រូវលើសពី ៣ ឆ្នាំឡើយ មេបាដែលមានកូនច្រើន និងគ្មានជំងឺឆ្លង។ការជ្រើសរើសមេមាន់ ត្រូវមានរាងល្អ ខ្លាំង មាំ ជើងលឿងគ្មានជំងឺ និងសុខភាពល្អ ត្រូវមានអាយុ ៧ ខែឡើង និងមានទម្ងន់ច្រើនជាង ១,២ គីឡូក្រាមរើសចេញពីមេមាន់ដែលបានផ្តល់កូន ៤ សារក្នុងមួយឆ្នាំយ៉ាងតិច ពងមួយសារពី ១០ ទៅ ១២ ពងហើយអត្រាញាស់ពី ៨ ក្បាលឡើង ហើយកូនមាន់ ទាំងនោះត្រូវតែសកម្ម និងត្លៀវក្លា។ កសិករ **វិន ប៊ុនលឿ** បានបន្តទៀតថា មេ និងបា គួរមានស្រកាជើងក្រាស់ល្អ ជើងមាំ សិរក្រហមស្បែកកស្តើងទន់ ។ បា១ក្បាល សម្រាប់មេ៦ ទៅ ៧ ក្បាល។



កសិករ វិន ប៊ុនលឿ កំពុងថែទាំកូនមាន់ ក្រោយយកចេញពីទូភ្ញាស់



ពូជមាន់ដែលកសិករ វិន ប៊ុនលឿ បានជ្រើសរើស យកមកចិញ្ចឹម

ចំពោះការសាងសង់ទ្រុងវិញ ដំបូងត្រូវជ្រើសរើសទីកន្លែងដែលមានទីទូល ឬមិនលិចទឹក ហើយចាក់ដីបំពេញឱ្យបានខ្ពស់ជាងផ្ទៃដីធម្មតា ដោយបុកបង្ហាប់ល្អ ដើម្បីជៀសវាងកុំឱ្យទឹកភ្លៀងហូរកាត់ក្នុងទ្រុង ។ ចំពោះផ្ទៃដីដែលចាក់នេះត្រូវធំជាងតួរោង ០,៥ ម៉ែត្រ ជុំវិញ។ ទំហំរោងមាន់ (ទ្រុងដេកយប់) ៥ម x ១០ម ហើយខ័ណ្ឌចែកដោយសំណាញ់ខាងក្រៅរោងព័ទ្ធសំណាញ់ កុំឱ្យមាន់ចេញក្រៅតួរោង និងសសរធ្វើពីឈើ ជញ្ជាំងទ្រុងធ្វើពីបន្ទះឫស្សី ដែលគម្លាតពីមួយទៅមួយប្រវែង ១ ស.ម ទ្រុងមានកម្ពស់ជើងរៀង១,៧ ម និងសសរកណ្ដាលកម្ពស់ ៣,២ ម ដំបូលគួរធ្វើពីស្បូវ ឬពីស្លឹកត្នោត គ្រោងទ្វារធ្វើពីកូនឈើ ឬ ពីឫស្សីដាក់ទ្រនំដេកកម្ពស់ពីដី ៧០ ស.ម និងមានបន្ទារធ្នើរ ៧០ ស.ម សំបុកសម្រាប់មេមាន់ពង ត្រូវនៅខ្ពស់ជាងទ្រនំដេក ត្រូវធ្វើជណ្ដើរសម្រាប់មេមាន់ឡើងក្រាបពង និង មាន់ឡើងដេក។



តួរោងទាំងមូលរបស់ទ្រុងមាន់



ធ្នើរទ្រនុំសម្រាប់មាន់ដេកធ្វើពីបន្ទះឫស្សី

ចំពោះការធ្វើអនាម័យកន្លែងចិញ្ចឹម កសិករ **វិន ប៊ុនលៀ** បានរៀបរាប់ប្រាប់ថា ត្រូវសម្អាតព្រៃជុំវិញកន្លែង (ទ្រុង)ចិញ្ចឹម លប់ដីគ្រលុកដក់ទឹកឱ្យបានស្អាតល្អ ត្រូវក្រាលបាតទ្រុងជាមួយអង្កាម ឬកំទេចអាចម៍រណារក្នុងកន្លែងមាន់ដេក(ទ្រុង) ត្រូវបោសសំអាតកើបលាមកមាន់ចេញរាល់ថ្ងៃត្រូវសម្លាប់មេរោគ និងបរាសិត (ក្នុងទ្រុង និងទីធ្លាចិញ្ចឹម)រៀងរាល់មុនពេលដាក់មាន់ យ៉ាងតិច ១អាទិត្យ ដោយបាចកំបោរសដើម្បីកុំឱ្យមាន់ឆ្លងមេរោគ មិនត្រូវយកទឹកកខ្វក់មកឱ្យមាន់ផឹកឡើយ ត្រូវផ្លាស់ប្ដូរទឹកថ្មីមួយដងក្នុងមួយថ្ងៃ ចំណីជុះផ្សិត ផ្អូម មិនត្រូវផ្ដល់ឱ្យមាន់ស៊ីទេ ត្រូវរៀបចំដាក់តាមប្រភេទ និងជំនាន់ (អាយុ) របស់វា (ក្រុមមេបា ក្រុមកូនជំទង់ និងក្រុមកូនតូចៗ ជាដើម)។ មាន់ទិញ ឬយកមាន់ចូលថ្មី ត្រូវរក្សាទុកវាដោយឡែកដាច់ពីគេចំនួន១៤ ថ្ងៃ បន្ទាប់មក បើសង្កេតឃើញវាមានសុខភាពល្អ ទើបដាក់ចូលជាមួយមាន់ចាស់បាន។មុនពេលចូលក្នុងទ្រុងមាន់ ត្រូវសម្លាប់មេរោគ ពិសេសដោយទឹកកំបោរជ្រលក់ស្បែកជើង ដែលមានដាក់នៅមាត់ច្រកចូល ជាមុនសិន។ ហាមមិនឱ្យមនុស្សពីក្រៅ (អ្នកដើរទិញមាន់ អ្នកចិញ្ចឹមកន្លែងផ្សេង) ចូលក្នុងកន្លែងចិញ្ចឹមមាន់ស្នូកទឹក ស្នូកចំណីត្រូវឧស្សាហ៍លាងសម្អាតជារៀងរាល់ថ្ងៃ ប្រសិនបើមាន់ងាប់ ត្រូវកប់ ឬ ដុតចោល មិនត្រូវបោះវាចោលពាសវាលពាសកាលនោះទេហើយ មិនត្រូវបរិភោគមាន់ដែលងាប់ដោយសារជំងឺទេ។



ការផ្ដល់ទឹកស្អាតដល់មាន់

ចំពោះចំណី ដែលគេប្រើសម្រាប់ផ្ដល់ជាចំណីបន្ថែមមានដូចជាចុងអង្ករ កន្ទក់ ជាចំណីផ្ដល់នូវថាមពល និងមានប្រូតេអ៊ីនពី ៨-១២% ហើយសំបូរផូស្វ័រ និងវីតាមីនបេចំពោះពោតកសិករកម្រប្រើណាស់ តែពោតជាប្រភេទចំណីមាន់